# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**
សំណុំរឿងរដ្ឋប្បវេណីលេខ ២០០
ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣
សញ្ញាណនៃរឿងក្តី៖
បណ្តឹងទាមទារប្រាក់
សាលក្រមលេខ ២២ឃ."/២២៣
ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣

## <u>តាងនាមប្រជារាស្ត្រខ្មែរ</u>
## សាលាដំបូងខេត្តសៀមរាប

- បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣ វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក ក្នុងបន្ទប់សវនាការលេខ៖ ខ.២ អាគារ ខ នៃ សាលាដំបូងខេត្តសៀមរាប។
- បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣។
- កាលបរិច្ឆេទនៃការប្រកាសសាលក្រមនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក នៅសាលាដំបូងខេត្តសៀមរាប។

### <u>ដោយមានសមាសភាព</u>
### ចៅក្រមជំនុំជម្រះ

- លោក [redacted] អនុប្រធាន និងជាចៅក្រមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

- លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

<u>សាលាដំបូងខេត្តសៀមរាប បានចេញសាលក្រមដែលមានតួភាគីដូចខាងក្រោម៖</u>

**ដើមចោទ** ៖ ឈ្មោះ [redacted] Jonathan ភេទប្រុស អាយុ៧០ ឆ្នាំ សញ្ជាតិអាមេរិក កាន់លិខិតឆ្លងដែនលេខ ៥៦៧៨២៨៧៥៤ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះវីឡា [redacted]

មេធាវីតំណាងដោយអាណត្តិ ៖ លោកមេធាវី [redacted] អត្តលេខ ២៦២៧T ជាមេធាវីនៃ ក្រុមមេធាវី [redacted] សាខា ខេត្តសៀមរាប មានអាសយដ្ឋានស្ថិតនៅ [redacted]។

**ចុងចម្លើយ៖** ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ៤២ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ១៨០៦០៣៩២០ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះវីឡា [redacted]។

**វត្ថុនៃពាក្យបណ្តឹង៖** ប្តឹងទាមទារប្រាក់តាមកិច្ចសន្យាខ្ចីប្រាក់។

(១)- <u>**អង្គហេតុ និងចំណុចវិវាទ**</u>

ក. <u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ</u> ៖



Scanned with CamScanner

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណៈ សងប្រាក់ជំពាក់ចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ១.៥% (មួយក្បៀសប្រាំ) ភាគរយក្នុងមួយខែ គិតចាប់ពីថ្ងៃខ្ចីរហូតដល់ថ្ងៃទូទាត់សងប្រាក់រួច មកឱ្យដើមចោទឈ្មោះ [redacted] Jonathan។

២. ទាមទារសំណងខូចខាត និងសេវាកម្មផ្នែកច្បាប់ ចំនួន USD ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក។

៣. ស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នលើគ្រប់ចំណុច។

៤ ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

ខ. ការពន្យល់ត្រួសៗអំពីរឿងក្តី៖

កាលពីអំឡុងខែធ្នូ ឆ្នាំ២០២២ លោក [redacted] វណ្ណៈ បានខ្ចីប្រាក់ពីខ្ញុំចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក សម្រាប់រយៈពេល ២ (ពីរ) ខែ ដោយគិតចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ តាមរយៈលិខិតផ្តល់ និងទទួល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។ លុះដល់កាលកំណត់សង ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់មកឱ្យដើមចោទឡើយ ដោយគិតចាប់ពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ មានរយៈពេលយឺតយ៉ាវចំនួន ៧៨ (ចិតសិបប្រាំបី) ថ្ងៃហើយ។

ដើមចោទ បានព្យាយាមទាក់ទងទៅកាន់ចុងចម្លើយ ដើម្បីឱ្យធ្វើការទូទាត់សងប្រាក់ជំពាក់ខាងលើនេះ ជាច្រើនលើកច្រើនសារ ប៉ុន្តែ ចុងចម្លើយតែងតែគេចវេះ និងព្យាយាមរកលេសអូសបន្លាយពេលវេលាសងប្រាក់ម្តងហើយម្តងទៀត ដោយពុំមានការឆ្លើយតប ឬការផ្តល់នូវមូលហេតុណាមួយសមរម្យនោះឡើយ។ ដើមចោទបានធ្វើការដាស់តឿនជាផ្លូវការទៅកាន់ចុងចម្លើយ អំពីការទូទាត់សងប្រាក់តាមរយៈលិខិតដាស់តឿន ០២៣/២៣ ACLG-SR ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ប៉ុន្តែចុងចម្លើយនៅតែមិនព្រមចូលមកដោះស្រាយ ឬបង្ហាញឆន្ទៈក្នុងការសងប្រាក់មកដើមចោទឡើយ។

**ដើមចោទសុំឲ្យតុលាការពិនិត្យភស្តុតាងជាឯកសារចម្លងដូចខាងក្រោម៖**

-លិខិតផ្តល់ និងទទួល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

- លិខិតដាស់តឿនលេខ ០៣២/២៣ ACLG-SR ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣។

- លិខិតទទួលស្គាល់ និងធានាអះអាង ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣។

គ. ចំណុចវិវាទនៃរឿងក្តី៖ គ្មាន ។

## (២)- **ការអះអាងរបស់ភាគី**

(០១)- សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទលោកមេធាវី [redacted] ថា ៖ ខ្លួនជាមេធាវីតំណាងដោយអាណត្តិភាគីដើមចោទ នៅតែរក្សាការទាមទាដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ដដែល ។ ដោយស្នើសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម ៖



Scanned with CamScanner

១. បង្គាប់ឱ្យចុងចម្លើយឆ្លើយឈ្មោះ [redacted] វណ្ណៈ សងប្រាក់ជំពាក់ចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ១.៥% (មួយក្បៀសប្រាំ) ភាគរយក្នុងមួយខែ គិតចាប់ពីថ្ងៃខ្ចីរហូតដល់ថ្ងៃទូទាត់សងប្រាក់រួច មកឱ្យដើមចោទឈ្មោះ [redacted] Jonathan។

២. ទាមទារសំណងខូចខាត និងសេវាកម្មផ្នែកច្បាប់ ចំនួន USD ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក។

៣. ស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នលើគ្រប់ចំណុច។

៤ ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

រូបខ្លួនសូមបញ្ជាក់បន្ថែមផងដែរថា កាលពីអំឡុងខែធ្នូ ឆ្នាំ២០២២ ចុងម្លើយ បានមកខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក សម្រាប់រយៈពេល ២ (ពីរ) ខែ ដោយគិតចាប់ពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ តាមរយៈលិខិតផ្តល់ និងទទួល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។ លុះដល់កាលកំណត់សងចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចសងប្រាក់មកឱ្យកូនក្តីខ្លួនឡើយ ដោយគិតចាប់ពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ មានរយៈពេលយឺតយ៉ាវចំនួន ៧៨ (ចិតសិបប្រាំបី) ថ្ងៃហើយ។

កូនក្តីខ្លួន បានព្យាយាមទាក់ទងទៅកាន់ចុងចម្លើយ ដើម្បីឱ្យធ្វើការទូទាត់សងប្រាក់ជំពាក់ខាងលើនេះ ជាច្រើនលើកច្រើនសារ ប៉ុន្តែចុងចម្លើយតែងតែគេចវេះ និងព្យាយាមរកលេសអូសបន្លាយពេលវេលាសង ប្រាក់ម្តងហើយម្តងទៀត ដោយពុំមានការឆ្លើយតប ឬការផ្តល់នូវមូលហេតុណាមួយសមរម្យនោះឡើយ។ កូនក្តីខ្លួនបានធ្វើការដាស់តឿនជាផ្លូវការទៅកាន់ចុងចម្លើយ អំពីការទូទាត់សងប្រាក់តាមរយៈលិខិតដាស់តឿន ០២៣/២៣ ACLG-SR ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ប៉ុន្តែចុងចម្លើយនៅតែមិនព្រមចូលមកដោះស្រាយ ឬបង្ហាញឆន្ទៈក្នុងការសងប្រាក់មកដើមចោទឡើយ។

កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ [redacted] វណ្ណៈ បានធ្វើលិខិតទទួលស្គាល់ និងធានាអះអាងថា គាត់ពិតជាបានខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន USD ២០.០០០(ពីរម៉ឺន) ដុល្លារអាមេរិក ពិតមែន។ ហើយចុងចម្លើយយល់ព្រមផ្ទេរនូវកម្មសិទ្ធិលើអចលនវត្ថុ (ដីឡូតិ៍) មួយកន្លែង មានតម្លៃចំនួន USD ១៥.០០០ (មួយម៉ឺន ប្រាំពាន់) ដុល្លារអាមេរិក ទំហំផ្ទៃក្រឡាសរុបចំនួន ១៨៣ (មួយរយសែសិបបី) ម៉ែត្រការ៉េ ឡូតិ៍លេខ A14 មានទីតាំងស្ថិតនៅភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៩៦៨ ចេញដោយប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប មកឱ្យកូនក្តីខ្លួន ដើម្បីធ្វើការកាត់កងបំណុលខាងលើ។ ប៉ុន្តែកូនក្តីខ្លួនទើបតែដឹងថា ដីនេះមិនមែនជាកម្មសិទ្ធិរបស់លោក [redacted] វណ្ណៈ ហើយអាចធ្វើការកាត់ឈ្មោះផ្ទេរកម្មសិទ្ធិស្របច្បាប់មកឱ្យកូនក្តីបានឡើយ។

ដោយឡែក ចំពោះប្រាក់ជំពាក់ដែលនៅសល់ចំនួន USD ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដែល គាត់បានសន្យាសងរំលស់ជាប្រចាំខែចំនួន USD ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់រយៈពេលនៃការទូទាត់សងគឺចំនួន ១០ (ដប់)ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ



Scanned with CamScanner

២០២៣ រហូតដល់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ ក៏គាត់មិនបានអនុវត្តកាតព្វកិច្ចទូទាត់សង ដូចមាននៅក្នុងលិខិតទទួលស្គាល់ និងធានាអះអាងខាងលើឡើយ។

(០២)- សេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] សុវណ្ណៈ នៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានធ្វើសេចក្តីថ្លែងការណ៍តបវិញថា ៖ រូបខ្លួនទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់ចំនួន ២០.០០០ ដុល្លារអាមេរិក ពិតប្រាកដមែន ។ មូលហេតុដែលខ្លួនមិនទាន់ធ្វើការទូទាត់សងប្រាក់ជូនគាត់ដោយហេតុថាគាត់ជួលផ្ទះ (មួយបន្ទប់) របស់ខ្លួនក្នុងមួយខែ ១៨០ ដុល្លារអាមេរិក ក្នុងរយៈពេល ២១ខែ។ ដោយការស្នាក់នៅរបស់គាត់មិនបានបង់ថ្លៃឈ្នួលឲ្យខ្លួនអស់រយៈ២១ខែមកហើយ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ បន្ទាប់ពីគាត់បានជួលនៅមួយរយៈក្រោយមក គាត់ក៏បានសម្រេចចិត្តជួលអាគាររបស់ខ្លួនទាំងមូលតែម្តងក្នុងតម្លៃ២០.០០ដុល្លារ ក្នុងមួយខែ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ និងត្រូវកក់ប្រាក់ ៦.០០០ ដុល្លារអាមេរិក ស្មើ៣ខែ ដោយមិនបានទូទាត់ប្រាក់ឈ្នួលនៅឡើយទេ ។

នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ Jonathan បានរើចេញពីបន្ទប់ដោយមិនបានជូនដំណឹងមកខ្លួននោះទេ។ ចំពោះប្រាក់ដែលឈ្មោះ Jonathan បានឲ្យខ្លួនខ្ចីគឺខ្លួនបានប្រាប់គាត់ថាមួយរយៈពេលនេះខ្លួនខ្វះខាតប្រាក់ ស្រាប់តែឈ្មោះ Jonathan បានយកប្រាក់មកឲ្យខ្លួនខ្ចីចំនួន ០៣លើក ដោយលើកទី០១ គឺបីពាន់ ដុល្លារអាមេរិក, លើកទី២ ប្រាំពីរពាន់ដុល្លារអាមេរិក និងលើកទី៣ គឺមួយម៉ឺនដុល្លារអាមេរិក (ប្រាក់ដែលឈ្មោះ Jonathan បានប្រគល់ប្រាក់ឲ្យខ្លួននេះក្នុងន័យគាត់ទិញដីខ្លួនក្នុងអត្តន័យយោគយល់ ប្រសិនខ្ញុំលក់ដីបានវិញពេលណាខ្ញុំនឹងសងគាត់វិញ ពេលនោះ) ។

រូបខ្លួនស្នើសុំបដិសេធចោលទាំងអស់នៃការទាមទារក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ដោយស្នើសុំឲ្យសុំភាគីដើមចោទដោះស្រាយលើកិច្ចសន្យាជួលសិន ខ្លួនក៏សុំបដិសេធចំពោះការលើកឡើងរបស់លោកមេធាវីដែលលើកឡើងថា លោកJonathan បានបង់ថ្លៃឈ្នួលជារៀងរាល់ខែ គាត់បានបង់រាល់ខែពិតមែន តែគាត់បង់តែលើថ្លៃទឹក ភ្លើងតែប៉ុណ្ណោះ។ ការលើកឡើងរបស់លោកមេធាវីដែលបានលើកឡើងថា ឯកសារដែលជាកិច្ចសន្យាជួលរវាង លោក Jonathan និងលោកស្រី [redacted]Fan មិនពាក់ព័ន្ធខ្លួនគឺមិនត្រឹមត្រូវទេ ព្រោះលោកស្រី [redacted]Fan បានផ្ទេរសិទ្ធិឲ្យខ្លួនជាអ្នកដោះស្រាយជំនួស តាមលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។ ខ្លួននៅតែសំណូមពរថា ឲ្យមានការទូទាត់គ្នាដើម្បីបញ្ចប់រឿង។ ខ្លួនសូមបញ្ជាក់បន្ថែមថា កិច្ចសន្យាជួលអាគារ ជាឬសគល់នៃកិច្ចសន្យាទទួលស្គាល់ និងធានាអះអាង ។

នាពេលទាញហេតុផលដោយផ្ទាល់មាត់

ចុងចម្លើយឈ្មោះ [redacted] វណ្ណៈ អវត្តមានដោយគ្មានមូលហេតុត្រឹមត្រូវ ដោយតុលាការបានធ្វើការបញ្ជូនដីកាកោះត្រឹមត្រូវតាមនីតិវិធី ហើយភាគីចុងចម្លើយបានទទួលដីកាកោះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ដប់ និងប្រាំនាទីព្រឹក តាមរបាយការណ៍បញ្ជូនចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ



Scanned with CamScanner

២០២៣ ប៉ុន្តែនៅថ្ងៃកំណត់ចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២៣ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក ភាគីចុងចម្លើយខាងលើបែរជាអវត្តមានដោយគ្មានមូលហេតុទៅវិញ ។

## សំអាងហេតុ

**តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងពិនិត្យភស្តុតាងតុលាការយល់ឃើញថា៖**

(០១)- ពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ របស់លោកដើមចោទឈ្មោះ [redacted] Ray Jonathan ធ្វើឡើងត្រឹមត្រូវតាមមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ហើយសាលាដំបូងខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះក្តីយោងតាមមាត្រា៨ មាត្រា៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(០២)- លិខិតតំណាងដោយអាណត្តិ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ របស់លោកមេធាវី [redacted] ដែលជាអ្នកតំណាងដោយអាណត្តិធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា៥២ មាត្រា៥៣ និងមាត្រា៥៤ ជាអាទិ៍ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(០៣)- ភាគីចុងចម្លើយឈ្មោះ [redacted] វណ្ណៈ និង ដើមចោទឈ្មោះ [redacted] Jonathan ពិតជាមានទំនាក់ទំនងគតិយុត្តលើកិច្ចសន្យាប្រាក់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ក្នុងទំហំសាច់ប្រាក់ដើមនៃកម្ចីចំនួន USD ២០០០០ (ពីរម៉ឺន ដុល្លារអាមេរិក) មានអត្រាការប្រាក់១.៥%ក្នុងមួយខែ ពិតប្រាកដមែន។

(០៤)- ភាគីចុងចម្លើយឈ្មោះ [redacted] វណ្ណៈ ទទួលស្គាល់ថាខ្លួនពិតជាជំពាក់ប្រាក់ដើមចោទឈ្មោះ [redacted] Jonathan ចំនួន USD ២០.០០០ (ពីរម៉ឺន ដុល្លារអាមេរិក) និងការប្រាក់ ដោយមិនទាន់បានសងទៅឲ្យដើមចោទពិតប្រាកដមែន ។

(៥)- ចុងចម្លើយបដិសេធមិនព្រមសងប្រាក់ដែលខ្លួនជំពាក់ទៅឲ្យភាគីដើមចោទ ដោយលើកមូលហេតុថាភាគីដើមចោទ បានជួលផ្ទះ (មួយបន្ទប់) របស់ខ្លួនក្នុងមួយខែ ១៥០ដុល្លារអាមេរិក ក្នុងរយៈពេល ២១ខែ ដោយការស្នាក់នៅរបស់ដើមចោទមិនបានបង់ថ្លៃឈ្នួលឲ្យខ្លួន អស់រយៈ២១ខែមកហើយ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ បន្ទាប់ពីដើមចោទបានជួលអាគារនៅមួយរយៈក្រោយមក ដើមចោទក៏បានសម្រេចចិត្តជួលអាគាររបស់ចុងចម្លើយទាំងមូលតែម្តងក្នុងតម្លៃ២០០០ដុល្លារ ក្នុងមួយខែ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣ និងត្រូវកក់ប្រាក់ ៦០០០ ដុល្លារអាមេរិក ស្មើ៣ខែ ដោយរហូតមកដល់ពេលនេះភាគីដើមចោទមិនបានទូទាត់ប្រាក់ឈ្នួលនៅឡើយទេ ។

ការលើកឡើងរបស់ភាគីចុងចម្លើយនាដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផលតុលាការយល់ឃើញថា ការបដិសេធពីសំណាក់ភាគីចុងចម្លើយ មិនព្រមសងប្រាក់ដែលខ្លួនជំពាក់ភាគីដើមចោទចំនួន USD ២០០០០ (ពីរម៉ឺនដុល្លារអាមេរិក) ដោយលើមូលហេតុថាភាគីដើមចោទបានជួលអាគាររបស់ខ្លួនដោយមិនបានបង់ថ្លៃឈ្នួលឲ្យខ្លួន ត្រង់ចំណុចនេះតុលាការយល់ឃើញថាជាកិច្ចសន្យាពីរផ្សេងគ្នា មួយជាកិច្ចសន្យាខ្ចីបរិភោគ ដែលស្របតាមបញ្ញត្តិមាត្រា៥៧៨ ដល់មាត្រា៥៩៥ នៃក្រមរដ្ឋប្បវេណី និងមួយទៀតជា ភតិសន្យាស្របតាមបញ្ញាត្តិមាត្រា៥៩៦ ដល់មាត្រា៦២១ នៃក្រមរដ្ឋប្បវេណី ហេតុនេះគប្បីតុលាការមិនពិចារណាចំពោះការលើកឡើងរបស់ភាគីចុងចម្លើយឡើយ។



Scanned with CamScanner

(៦)- ចំណុចទី២ នៃកម្មវត្ថុបណ្តឹងស្តីពីការទាមទារសំណងជម្ងឺចិត្ត និងសេវាកម្មផ្នែកច្បាប់ចំនួន USD១០០០០ (មួយម៉ឺនដុល្លារអាមេរិក)។ ឃើញថាការទាមទាររបស់មេធាវីតំណាងដោយអាណត្តិត្រង់ចំណុចនេះមិនមានមូលដ្ឋានទាមទារច្បាស់លាស់ ដែលបញ្ជាក់ពីទំហំការខាតបង់របស់ភាគីដើមចោទនោះទេ។ ហើយការបដិសេធមិនព្រមសងការខាតបង់តបនឹងការទាមទារពីសំណាក់ភាគីចុងចម្លើយ ក៏មិនសមរម្យផងដែរ។ តុលាការនឹងពិនិត្យលើសេវាកម្មបង់ពន្ធ តាមច្បាប់ ការចំណាយលើសេវាកម្មមេធាវី និងការបង់ខាតពេលវេលារបស់ដើមចោទជាអាទ័មកធ្វើជាមូលដ្ឋាននៃការសម្រេចពីការខូចខាតរបស់ដើមចោទផ្អែកលើភាពសមរម្យ។

(៧)- កម្មវត្ថុបណ្តឹងស្តីពីបន្ទុកនៃការបង់ប្រាក់ប្រដាប់ក្តីតុលាការ។ ផ្អែកតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តីតុលាការ បានកំណត់ជាបន្ទុករបស់ភាគីចុងចម្លើយ។ ហេតុនេះ គប្បីបង្គាប់ឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកលើប្រាក់ ប្រដាប់ក្តីតុលាការទាំងអស់តាមច្បាប់ជាធរមាន។

(៨)-កម្មវត្ថុបណ្តឹងស្តីពីការស្នើសុំអនុវត្តជាបណ្តោះអាសន្នចំណុចទី១នៃសាលក្រមលើប្រាក់ដើម តុលាការយល់ឃើញថា ទំហំប្រាក់ដើមចំនួន USD ២០០០០ (ពីរម៉ឺនដុល្លារអាមេរិក) ដែលមិនទាន់បានសងនេះ ភាគីចុងចម្លើយបានព្រមព្រៀងទទួលស្គាល់ហើយ ។ ភាគីដើមចោទទាមទារឲ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្ន ដើម្បីជៀសវាងការខូចខាតប្រយោជន៍ម្ចាស់បំណុលកាន់ច្រើនបន្ថែមទៀត។ តាមការទាមទាររបស់ដើមចោទហើយចំណុចស្តីពីប្រាក់ដើម ភាគីបានព្រមព្រៀង តុលាការយល់ឃើញថាមានភាពចាំបាច់ដើម្បីប្រកាសអនុវត្តបណ្តោះអាសន្នលើចំណុចទី១ស្តីពីប្រាក់ដើមនេះស្របតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] វណ្ណៈ សងប្រាក់ជំពាក់ចំនួន USD ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ១.៥% (មួយក្បៀសប្រាំ) ភាគរយក្នុងមួយខែ គិតចាប់ពីថ្ងៃខ្ចីរហូតដល់ថ្ងៃទូទាត់សងប្រាក់រួច មកឱ្យដើមចោទឈ្មោះ[redacted] Jonathan។

២.ឱ្យសហចុងចម្លើយឈ្មោះ[redacted]វណ្ណៈ សងសំណងខូចខាត និងសេវាកម្មផ្នែកច្បាប់ ចំនួន ១០.០០០.០០០ (ដប់លាន) រៀល។ ការទាមទារលើសពីនេះបដិសេធចោល។

៣. សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នត្រង់ចំណុចទី១ លើប្រាក់ដើមចំនួន USD ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក នៃសេចក្តីសម្រេច។

៤. ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រមជាសាធារណៈចំពោះមុខភាគីដើមចោទ និងកំបាំងមុខភាគីចុងចម្លើយឈ្មោះ [redacted] វណ្ណៈ ។



Scanned with CamScanner

ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និងត្រា ៖ [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៣កើតខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

សៀមរាប, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]